# សេចក្តីប្រកាសព័ត៌មាន
# គណៈកម្មការត្រួតពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៧ គណៈកម្មការបានបញ្ចប់កិច្ចប្រជុំរយៈពេល ១០ ថ្ងៃ ស្តីពីសេចក្តីព្រាងវិធានផ្ទៃក្នុង នៅទីក្រុងភ្នំពេញ។

ក្នុងអំឡុងពេលកិច្ចប្រជុំនេះ គណៈកម្មការបានពិភាក្សានូវចំណុចលំអិត១ជាច្រើន និង បានដោះស្រាយទាំងអស់នូវបញ្ហាដែលមិនទាន់បានឯកភាពគ្នា ប៉ុន្តែនៅមានកិច្ចការមួយចំនួនទៀតដែលត្រូវធ្វើ គឺដើម្បីកែលំអពាក្យពេជន៍សេចក្តីព្រាងវិធានផ្ទៃក្នុង ឱ្យមានខ្លឹមសារកាន់តែល្អប្រសើរ។

ប៉ុន្តែបញ្ហាមួយដែលមិនមានចែងក្នុងសេចក្តីព្រាងវិធានផ្ទៃក្នុង នៅតែជាបញ្ហាប្រឈមនោះ គឺឥទ្ធិពលនៃការកំណត់តំលៃលើការចុះឈ្មោះរបស់មេធាវីបរទេសនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ចៅក្រមអន្តរជាតិ យល់ឃើញថា សេចក្តីសំរេចចុងក្រោយរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការកំណត់តំលៃនៃការចុះឈ្មោះ មិនអាចទទួលយកបានទេ ហើយយល់ឃើញថា តំលៃនេះជាការកំរិតដ៏ធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនជាប់ចោទ និង ជនរងគ្រោះក្នុងការជ្រើសរើសមេធាវី ។ ចៅក្រមអន្តរជាតិជឿជាក់ថា ការកំណត់តំលៃចុះឈ្មោះមិនសមរម្យនេះ បង្កើតទៅជាឧបសគ្គដល់ការអនុម័តវិធានផ្ទៃក្នុង នៅពេលដែលចៅក្រមជាតិ យល់ឃើញថា តំលៃចុះឈ្មោះនេះ គឺជាបញ្ហាមួយនៅក្រៅសមត្ថកិច្ចរបស់សេចក្តីព្រាងវិធានផ្ទៃក្នុង និង មិនអាចក្លាយជាឧបសគ្គដល់ការអនុម័តវិធានផ្ទៃក្នុងទេ ។ ចៅក្រមទាំងអស់បានត្រៀមខ្លួនដើម្បីរៀបចំកិច្ចប្រជុំពេញអង្គ នៅចុងខែមេសានេះ។ សំរាប់ចៅក្រមអន្តរជាតិ កិច្ចប្រជុំពេញអង្គ អាចរៀបចំទៅបានដរាបណាមានដំណោះស្រាយសមស្របមួយលើបញ្ហានេះ។

ដើម្បីស្វែងរកដំណោះស្រាយមួយសមស្របដែលអាចទទួលយកបានពីគ្រប់ភាគីទាំងអស់ សម្រាប់ឱ្យកិច្ចប្រជុំពេញអង្គ អាចរៀបចំទៅបាន នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៧ សូមស្នើឱ្យគណៈមេធាវីនៃព្រះរាជណាចក្រកម្ពុជា ពិចារណាឡើងវិញលើជំហររបស់ខ្លួន ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន និង ស្នើឱ្យអង្គភាពគាំពារការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ ធ្វើការឱ្យជិតស្និទ្ធជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងបញ្ហា ។

សមាជិកទាំងអស់របស់គណៈកម្មការ បន្តប្តេជ្ញាចិត្តក្នុងការខិតខំប្រឹងប្រែងសំរេចឱ្យបានជោគជ័យលើការងារ ក៏ស្មុគស្មាញក្នុងការច្របាច់បញ្ចូលគ្នានូវច្បាប់ជាតិ និងអន្តរជាតិ ដើម្បីធ្វើឱ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អាចបំពេញភារកិច្ចជាប្រវត្តិសាស្ត្ររបស់ខ្លួន ក្នុងការស្វែងរកយុត្តិធម៌ដល់ប្រជាពលរដ្ឋកម្ពុជា។